**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១១៧.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារទទួលបន្ទុកកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងវិនិយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារទទួលបន្ទុកកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងវិនិយោគ ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២. | តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥. | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦. | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៧. | តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨. | តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៩. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០. | តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១. | ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងការជំរុញគម្រោងវិនិយោគឯកជន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

តំណាងក្រសួងនីមួយៗដែលជាសមាជិកនៃក្រុមការងារត្រូវមានឋានៈចាប់ពីអគ្គនាយករងឡើងទៅ។

**ប្រការ២.-**

ក្រុមការងារទទួលបន្ទុកកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងវិនិយោគ មានតួនាទីនិងភារកិច្ចដូចតទៅ÷

១. ពង្រឹងទំនាក់ទំនង សម្របសម្រួល ពិភាក្សាផ្លាស់ប្តូរព័ត៌មានស្តីពីគោលនយោបាយ និងផ្តល់អនុសាសន៍សម្រាប់ជំរុញកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងវិនិយោគ

២. រៀបចំផែនការសម្រាប់គម្រោងវិនិយោគដែលអាចអនុវត្តបានក្រោមកិច្ចសហប្រតិបត្តិការទ្វេភាគី

៣. សម្របសម្រួលរៀបចំបញ្ជីគម្រោងអាទិភាព និងជំរុញគម្រោងអាទិភាពគន្លឹះ ដោយសម្របសម្រួលដោះស្រាយបញ្ហាប្រឈមក្នុងដំណើរការនៃការអនុវត្តគម្រោង ព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការលើកកម្ពស់សមត្ថភាពផលិត និងវិនិយោគ។

**ប្រការ៣.-**

សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនតំណាងដើម្បីដឹកនាំប្រជុំជំនួស។

**ប្រការ៤.-**

ក្រុមការងារនេះអាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន អ្នកជំនាញការ ឬភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ៥.-**

ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបំពេញការងាររបស់ខ្លួន។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាម៉ីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ